

# ឃ្មុំភ្នែកធំ

Iem Tithseiha

Sou Kimsan

Let's Read

The Asia Foundation



សុភីជាឃ្មុំមានភ្នែកធំៗជាងគេ។ នាងអាចមើលបានឆ្ងាយ និងច្បាស់។ ស្លាបនាងខ្លីៗតែនាងអាចហើរលឿនជាងគេ។ សុភីតែងតែហើរទៅក្រេបយកទឹកដមផ្កាមុនគេជានិច្ច។ ថ្ងៃនេះនាងហើរចេញទៅក្រៅដូចសព្វមួយដង។



សុភីហើរមកដល់សួនផ្កាក្បែរមាត់ទឹក។ នាងទំលើផ្កាមួយធំជាងគេ។ នាងក៏រអ៊ូថា «ហេតុអ្វីពួកគេហើរយឺតម្ល៉េះ? ខ្ញុំមកដល់យូរហើយ។» ក្លិនផ្កាដ៏ក្រអូបធ្វើឱ្យនាងរំភើបចិត្ត។ នាងបិទភ្នែកបណ្ដើរ លោតរាំចុះឡើងបណ្ដើរ «អ្ហា! ក្រអូបណាស់។»



បន្តិចក្រោយមក ហ្វូងឃ្មុំទាំងអស់ក៏មកដល់។ ពួកគេនាំគ្នាហើរជាក្រុមទៅរកផ្កាក្នុងសួននេះ។ ឃ្មុំក្បាលធំមួយក៏ហើរមកក្បែរសុភី រួចសួរថា៖ «សុភី! ម៉េចក៏ឯងមិនហើរជាមួយយើង?» សុភីក៏សើចចំអកថា៖ «ពួកឯងយឺតណាស់ គួរតែរៀនហើរឱ្យដូចខ្ញុំ។» ឃ្មុំក្បាលធំអន់ចិត្តក៏ហើរចេញទៅរកឃ្មុំដទៃ។



សុភីហើរឡើងខ្ពស់ ហើយនិយាយថា៖ «ចាំមើល៍ ខ្ញុំនឹងប្រមូលទឹកដមឱ្យច្រើនជាងគេ!» ថារួចនាងក៏ហើរចុះមកដណ្ដើមទឹកដមផ្កា។ នាងហើរប្រមូលពីផ្កាមួយទៅផ្កាមួយ។ នាងមិនរវីរវល់នឹងអ្នកដទៃទេ។ ជួនកាលសុភីភ្លក់ទឹកដមដែលដក់នៅចុងកេសរផ្កា។



ព្រះអាទិត្យរៀបលិច សំឡេងប៊ឺៗឮពេញសួនផ្កា។ ឃ្មុំទាំងអស់ខំសស្រាក់សស្រាំប្រមូលទឹកដម។ សុភីបិទឆ្នុកបំពង់ ហើយស្រែកប្រាប់ថា៖ «បងប្អូន! បំពង់ខ្ញុំពេញហើយ!» ឃ្មុំឯទៀតមិនរវល់នឹងនាងឡើយ។ សុភីទំលើផ្ការំយោលគិតថា៖ «ខ្ញុំគួរសម្រាកលេងបន្តិចសិន។»



សុភីដេកសម្លឹងផ្ទៃមេឃដ៏ស្រស់ស្អាត។ រំពេចនោះស្រាប់តែនាងឃើញផ្កាពណ៌ស្វាយមួយធំចម្លែក។ នាងរំភើបចិត្តណាស់ក៏គិតថា ផ្កានេះច្បាស់ជាមានទឹកដមច្រើនផ្អែមឆ្ងាញ់មិនខាន។ មិនបង្អង់យូរ នាងក៏ហើរសំដៅវាមួយរំពេច។



សុភីហើរតាមចន្លោះមែកឈើដែលពពាក់ពពូនគ្នា។ មែកខ្លះកោងចូលក្នុង ខ្លះទៀតកោងចេញក្រៅ។ នាងហើរចូលប្រហោងស្លឹកឈើដង្កូវស៊ី រួចក៏បុកតំណក់ទឹកដែលជាប់នៅចុងស្លឹកឈើ។ «ហាហា ពិតជាត្រជាក់ស្រួលមែន!»



រំពេចនោះសុភីក៏បង្អង់ល្បឿន។ នាងឃើញសត្វមួយគួរឱ្យខ្លាចកំពុងនៅលើសំណាញ់មុខនាង។ មេពីងពាងសួរដោយសំឡេងបង្អួសវែងៗថា៖ «នាងមិនដែលឃើញពីងពាងទេឬ?» «ពីងពាង? ខ្ញុំមិនដែលឃើញទេ...!» សុភីប្រញាប់ឆ្លើយ។



មេពីងពាងលួងលោមថា៖ «ឯងចូលមកលេងសំណាញ់ខ្ញុំទេ សប្បាយណាស់!» មេពីងពាងរត់ចុះឡើងលើសំណាញ់។ ឃើញដូច្នេះ សុភីចង់ទៅលេងដែរ។ នាងក៏ហើរសំដៅសរសៃពីងពាង។





គ្រាន់តែដល់ភ្លាម នាងឃើញមូសមួយកំពុងជាប់រើខ្លួនព្រួច។ សុភីក៏បង្វិលខ្លួនគេចតាមប្រឡោះសំណាញ់យ៉ាងរហ័ស ប៉ុន្តែជើងម្ខាងរបស់នាងជាប់ស្អិតដោយសរសៃពីងពាង។



មេពីងពាងហាមាត់បញ្ចេញចង្កូមសំដៅរកសុភី។ សុភីភ័យញាប់ញ័រយ៉ាងខ្លាំង។ នាងប្រឹងបម្រះទទះស្លាបខ្លាំងៗ។ «ខ្ញុំជាឃ្មុំលឿនជាងគេខ្ញុំត្រូវតែចេញឱ្យបាន។» ពីងពាងជិតមកដល់សុភីក៏បម្រះចេញរួចល្មម។





នាងត្រេកអរណាស់ ហើយក៏ហើរសំដៅផ្កាចម្លែកនោះ។ នាងបើកភ្នែកធំៗមើលផ្កាចម្លែក។ «ស្អាតខ្លាំងណាស់!» នាងនិយាយ។ ថារួចនាងក៏ប្រញាប់ក្រេបលម្អងផ្កានោះ (ពន្លឺដូចមាស)។ «អ្ហ៎!!! រសជាតិអីអាក្រក់ម្ល៉េះ?» ទឹកដមផ្កាល្វីងក្រពុលធ្វើឱ្យនាងវិលមុខ។ ភ្នែកធំៗរបស់នាងចាប់ផ្ដើមស្រវាំង។



តាមពិតវា គឺជាផ្កាពិសដែលចាប់សត្វល្អិតជាអាហារ។ ឃ្មុំភ្នែកធំខំហើរចេញពីស្រទាប់ផ្កា ប៉ុន្តែនាងក៏ចាប់ផ្តើមអស់កម្លាំង។ ស្លាបនាងក៏ទន់ ភ្នែកនាងបិទបន្តិចម្តងៗ។ ទីបំផុត នាងសន្លប់បាត់ស្មារតី។



នៅខាងក្រៅ ថ្ងៃចាប់ផ្ដើមលិច។ ហ្វូងឃ្មុំប្រមូលទឹកដមរួចរាល់។ ពួកគេគិតថាសុភីប្រហែលជាត្រឡប់ទៅសំបុកមុនហើយ។ ឃ្មុំទាំងអស់ក៏នាំគ្នាហើរចេញទៅ។





មេឃប្រែងងឹតស្ងាត់ជ្រងំ។ សំឡេងមួយបន្លឺឡើង «ភ្ញាក់ឡើងៗ!» សុភីបើកភ្នែកព្រឹមៗ ឃើញពន្លឺតូចមួយ។ នោះគឺសត្វអំពិលអំពែក។ អំពិលអំពែកខំជួយសុភីឱ្យខំទទះស្លាបហើរចេញ។ «ឆាប់ឡើង ខំហើរឱ្យខ្ពស់ឡើង!»



រំពេចនោះស្រាប់តែស្រទាប់ផ្កាបិទឃុំពួកគេជាប់។ ផ្កាក៏បញ្ចេញទឹកដែលមានក្លិនស្អុយមកកាន់តែច្រើន។ អំពិលអំពែកស្រែក «អូយថប់ដង្ហើមណាស់! យើងត្រូវស្លាប់នៅទីនេះមែនទេ?» សុភីក៏តបថា «ទេ! យើងត្រូវតែចេញពីទីនេះ។» ថារួចនាងខំបម្រះផង ទិចផ្កាផង។



ទីបំផុតពួកគេក៏អាចចេញមកក្រៅបាន។ ទាំងពីរនាក់អស់កម្លាំងដេកលើដី ។



ភ្លាមនោះ សត្វក្អែប កង្កែប និងខ្យាដំរី ក៏លេចចេញមកប្រុងស៊ីពួកគេ។ សុភី និងអំពិលអំពែកមិនអាចកម្រើកខ្លួនបានទេ។ ពួកគេភ័យយ៉ាងខ្លាំង។



សំណាងល្អ ហ្វូងឃ្មុំក៏មកដល់ល្មម។ ឃ្មុំមួយនិយាយមកកាន់សុភីថា៖ «ពួកយើងឃើញបំពង់ឯងទុកចោលក៏តាមរក! តោះឆាប់ឡើង!» ថារួចហ្វូងឃ្មុំក៏ស្ទុះទៅទិចសត្រូវ។ បន្ទាប់មកក៏នាំយកសុភី និងអំពិលអំពែកហើរចេញទៅ។



តាមផ្លូវ ហ្វូងឃ្មុំក៏វង្វេង ព្រោះងងឹតពេក ហើយមានគ្នាច្រើន។ អំពិលអំពែកក៏ហៅក្រុមរបស់គេមកជួយ។ ហ្វូងអំពិលអំពែកក៏ខំបំភ្លឺផ្លូវហ្វូងឃ្មុំ។ ឯសុភីខំបើកភ្នែកធំៗរបស់នាងប្រាប់ទិសដៅ។



ឃ្មុំទាំងអស់ហើរចេញផុតពីក្នុងព្រៃ។ ពន្លឺអំពិលអំពែក ភ្លឺបភ្លែតជាច្រើននៅលើទីវាល។សុភីនិយាយខ្សាវៗ «អរគុណ បងប្អូនណាស់! ខ្ញុំសូមទោសចំពោះរឿងកន្លងមក។» សុភី អំពិលអំពែក និងឃ្មុំទាំងអស់ញញឹមទៅរកគ្នា។ ក្រោមពន្លឺព្រះចន្ទលើមេឃ បរិយាកាស កាន់តែស្និទ្ធស្នាល។ ចប់

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Big-Eyed Bee*, Author: Iem Tithseiha. Illustrator: Sou Kimsan. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-4.0.

This work is a modified version of the original story. © The Asia Foundation, 2017. Some rights reserved. Released under CC-BY-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang